# វិហារវត្តទន្ទាប់

វត្តទន្ទាប់ ឬវត្តទន្ទាប់រង្សី ស្ថិតនៅក្នុងឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ បើយោងតាមសេចក្តីផ្សាយខ្ទីមួយរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យបញ្ជាក់ថា មកដល់បច្ចុប្បន្នវិហារវត្តទន្ទាប់មានអាយុ១១១ឆ្នាំ (កសាងឆ្នាំ១៩១០)។[១] ចំណែកឯការសិក្សារបស់ *Daniel Guéret* និង *Dominique-Pierre Guéret* បានកំណត់ថា វិហារនេះកសាងនៅក្នុងឆ្នាំ១៩២៨។[២] បើផ្អែកតាមសំណេរខ្ទីលើជញ្ជាំងខាងកើតចារថា "កសាងពីឆ្នាំឆ្លូវកាលពុទ្ធសកាពជ២៤៩២" ដែលកាលបរិច្ឆេទនេះ ត្រូវនឹងរវាងឆ្នាំ១៩៤៩ ពោលគឺមានអាយុកាល៧៣ឆ្នាំ ឯដាងគំនូរឈ្មោះផរ។

វិហារវត្តនេះ ជាស្ថាបត្យកម្មដ៏ចំណាស់មួយក្នុងនិគមជនបទ ដែលសេសសល់ពីសង្គ្រាម។ ទម្រង់វិហារមានលំនាំជាវិហារបុរាណ ដំបូលប្រក់ក្បឿងស្រកាលេញ ព្រមទាំងមានគំនូរបុរាណយ៉ាងល្អឆើត និយាយពីប្រធានបទល្អៗជាច្រើន លម្អនៅលើផ្ទៃពិដាន និងផ្ទៃជញ្ជាំងក្នុង-ក្រៅ។ តាមរយៈលក្ខណៈសំណង់គេយល់ថាជាសិល្បៈស្ថាបត្យកម្មព្រះពុទ្ធសាសនាខ្មែរមួយដ៏វិសេសគួរឱ្យចាប់អារម្មណ៍ ស្ថិតនៅចន្លោះខេត្តបាត់ដំបង និងសៀមរាប។ បច្ចុប្បន្នវិហារនេះបានជួសជុលអភិរក្សពង្រឹងគ្រឿងបង្គំខាងលើ ប្តូរក្បឿង ប្តូរការ៉ូកម្រាល និងលាបពណ៌តាមលំនាំដើម (រូបលេខ១-២)។



រូបលេខ១៖ ស្ថានភាពវិហារមុនជួសជុល
(ប្រភព៖ ជិម ផាក)



រូបលេខ២៖ វិហារក្រោយពេលជួសជុល

---

[១] ហ្វេសប៊ុកផេកផ្លូវការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១

[២] Daniel Guéret & Dominique-Pierre Guéret 2017: 147

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

វិហារវត្តទន្ទាប់ ជាវិហារជហ្វា៦ ដំបូលរាងជ្រាលថ្នាក់ៗបីជាន់ ទ្រដោយសសររបៀង ជុំវិញទាំងអស់ចំនួន៣៤ដើម សសរខាងក្នុងចំនួន១៦ដើម មានទ្វារចេញចូលខាងកើតពីរ ខាងលិចពីរ ខាងត្បូងពីរ ខាងជើងពីរ និងមានជណ្ដើរឡើងចុះទាំងបួនទិស។ គ្រឿងបង្គំ ដំបូលចាស់ គឺជាឈើប្រក់ក្បឿងស្រកាលេញ លម្អដោយក្បាច់ទ្រនុងនាគគ្រប់ចុងចែង ទាំងអស់។ ហោជាងខាងកើត រចនាដោយក្បាច់អង្គរលម្អជុំវិញរូបព្រះរាមផ្ទៃងសរឈរ ជាន់រាហ៊ូ (ព្រះកាល) (រូបលេខ២៣)។ ហោជាងខាងលិចលម្អដោយក្បាច់អង្គរ និងផ្ចិតយស តម្កល់នៅលើក្បាលរាហ៊ូខាំព្រះខ័ន អមដោយរាជសីហ៍ និងគជសីហ៍កាន់ឆ័ត្ររួត។ ចំណែកឯ នៅលើផ្ទៃផ្ចិតមានចារឹកអក្សរបីតួ "គនទ(?)" និងគាថាមួយឃ្លាថា "បញ្ញា ពុទ្ធោ វិរិយា ជិកា ហោមិ អណាគុតេកាលេ (?)" ដែលទំនងកាត់ន័យមកជាសេចក្ដីប្រាថ្នាថា "ខ្ញុំសូមមាន បញ្ញា ប្រកបដោយវិរិយភាព បានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល" (រូបលេខ២៤)។[៣]


រូបលេខ២៣៖ ហោជាងខាងកើត


រូបលេខ២៤៖ ហោជាងខាងលិច


រូបលេខ២៥៖ ឆាកប្រយុទ្ធ រវាងព្រះលក្ស្មណ៍ និងឥន្ទ្រជិត


រូបលេខ២៦៖ ឆាកប្រយុទ្ធ រវាងក្រុងរាពណ៍ និងអង្គទ


រូបលេខ២៧៖ ព្រះពុទ្ធសម្ដែង ធម្មទេសនា និងរូបអប្សរ ហោះហើរ


រូបលេខ២៨៖ ព្រះសង្ឃក្នុង ក្បួនធម្មយាត្រា (?) និង ឈុតស្វាប្រចាក់

[៣] ខ្ញុំសូមអរគុណលោកគ្រូ ម៉ិច ឃឿន ដែលបានជួយប្រែសម្រួលសេចក្ដីនេះ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះការគូរលម្អលើផ្ទៃជញ្ជាំងខាងកើត គឺជាឆាកប្រយុទ្ធគ្នារវាងព្រះលក្ស្មណ៍ និងឥន្ទ្រជិត(?)(រូបលេខ៥) អមដោយរូបទ្វារបាលសងខាង។ រីឯគំនូរលម្អជញ្ជាំងខាងលិច គឺជាឆាកប្រយុទ្ធដណ្តើមនាងសីតារវាងអង្គទ និងក្រុងរាពណ៍(?)[៤] (រូបលេខ៦)។ ការនិយមឆ្លាក់ ឬគូរឆាកប្រយុទ្ធក្នុងរឿងរាមកេរ្តិ៍លើផ្ទៃញ្ជាំងខាងមុខ ឬខាងក្រោយបែបនេះហាក់ពុំប្លែកអ្វីពីនៅលើជញ្ជាំងវិហារវត្តដំរីសខេត្តបាត់ដំបង ឬវិហារវត្តរាជបូព៌ ខេត្តសៀមរាបឡើយ។ រីឯនៅលើផ្ទៃជញ្ជាំងចំហៀង គេគូរលម្អដោយអន្ទើផ្សេងទៀតក្នុងរឿងរាមកេរ្តិ៍ ព្រះពុទ្ធសម្តែងធម្មទេសនា ព្រះសង្ឃក្នុងក្បួនធម្មយាត្រា(?) ទិដ្ឋភាពក្នុងសង្គមខ្មែរ និងចម្លាក់ពុម្ពតួអង្គក្នុងរឿងរាមកេរ្តិ៍ រូបទេវតា រូបស្វាប្រចាក់ និងរូបអប្សរក្នុងផ្ទៃក្បាច់ហោជាងលើស៊ុមទ្វារ និងបង្អួច (រូបលេខ៩-១១)។



រូបលេខ៩៖ គំនូរតូចៗបង្ហាញពីទិដ្ឋភាពសង្គ



រូបលេខ៖១០-១១ គំនូរទ្វារបាល

នៅផ្នែកខាងលិច សិល្បករលម្អរូបគ្រុឌត្រដាងស្វាបទ្រវេងស្បូវ ដើងទាំងពីរខ្ទាំកន្ទុយនាគមួយគូ ដែលព័ន្ធព័ទ្ធសសរសងខាងជណ្តើរ សណ្តូកខ្លួន បើកពពារធ្វើជាបង្កាន់ដៃជណ្តើរ (រូបលេខ១២)។ សូមកុំភ្លេចថា ក្នុងរឿងទេពកថាគ្រុឌជាជំនិះព្រះវិស្ណុ និងជាសត្រូវនឹងនាគ។[៥] ចំណែកក្បាលសសរផ្សេងទៀត ពុំមានលម្អរូបគ្រុឌ ឬកិន្នរដូចវិហារ

---

[៤] ជាធម្មតាតួអង្គក្រុងរាពណ៍មានមុខ១០ (ទសមុខ) ហើយក្នុងគំនូរច្រើនគូរដៃ៤ ឬ៨ ឬ១០ ឬ២០។ ប៉ុន្តែក្នុងរូបនេះគឺជាយក្សដែលមានដៃ២ មុខ១ តែសំណេរបញ្ជាក់ក្បែរនោះថាជាស្តេចរាពណ៍។

[៥] Jean Boisselier 1956: 105

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដទៃឡើយ (រូបលេខ១៣)។ ដោយឡែកនៅផ្នែកខាងក្នុងវិហារ គេគូរលម្អដោយគំនូរបុរាណលើពិដាន ឯពុទ្ធប្រវត្តិ និងទសជាតកលើផ្ទៃជញ្ជាំងជុំវិញ។ *Daniel Guéret* និង *Dominique-Pierre Guéret* យល់ថាគំនូរនេះគូរក្នុងឆ្នាំ១៩៤៥។[៦] ប៉ុន្តែយ៉ាងណាក៏ដោយ គេសង្កេតឃើញថា ឈុតខ្លះគំនូរពុទ្ធប្រវត្តិក្នុងវិហារវត្តទន្ទាប់ ហាក់មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងគំនូរក្នុងវត្តអំពិល ដែលស្ថិតនៅភាគខាងជើងក្បែរគ្នានេះដែរ (រូបលេខ១៤-១៨)។



រូបលេខ១២៖ រូបនាគ និងគ្រុឌទ្រទ្រង់ស្បូវខាងលិច



រូបលេខ១៣៖ ក្បាច់លម្អ និងសសរវិហារចំហៀង



រូបលេខ១៤៖ ទិដ្ឋភាពក្នុងវិហារ



រូបលេខ១៥៖ គំនូរលើពិដាន



រូបលេខ១៦៖ គំនូរលើជញ្ជាំង



រូបលេខ១៧៖ គំនូរទសជាតក



រូបលេខ១៨៖ គំនូររឿងពុទ្ធប្រវត្តិត្រង់សុបិននិមិត្ត និងព្រះអង្គប្រសូត្រ

[៦] Daniel Guéret & Dominique-Pierre Guéret 2017: 147

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដូច្នេះជារួមមក វិហារវត្តទន្ទាប់ គឺជាតឹកតាងសិល្បៈស្ថាបត្យកម្មបុរាណដ៏ល្អមួយនៅតាមស្រុកស្រែជនបទ ដែលមានក្បាច់រចនា និងគំនូរបង្ហាញពីប្រធានចម្រុះគ្នា។ ទន្ទឹមនឹងនេះ តាមរយៈគំនូរ និងចម្លាក់លម្អខ្លះនាំឱ្យយើងយល់បានថាការនិយមលើកយកឈុតឆាកវែងខ្លីនៃរឿងរាមកេរ្តិ៍ រឿងក្នុងជាតក និងរឿងពុទ្ធប្រវត្តិមកគូរបង្ហាញលើជញ្ជាំងវិហារ គឺជារឿងធម្មតាដែលសង្គមខ្មែរនិយមរាប់អានតាំងពីដើមរៀងមក ដែលគួរមានការសិក្សាស្រាវជ្រាវស៊ីជម្រៅ។

## ឯកសារយោង


Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

Boisselier Jean

1956, *Trends in Khmer*, Presses Universitaires de France, Art, p.105.


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត